# សេចក្តីថ្លែងការណ៍របស់ដៃគូអភិវឌ្ឍស្តីអំពីសូចនាករតាមដានរួមគ្នា

## នៅក្នុងកិច្ចប្រជុំលើកទី ១៩ របស់គណកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍

## ភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០១២

ដៃគូអភិវឌ្ឍន៍ សូមអបអរសាទររាជរដ្ឋាភិបាលកម្ពុជា ចំពោះការដាក់ចេញនូវដំណើរការដែលប្រកបដោយការចូលរួមនៅក្នុងការពង្រឹងការបង្កើត និងការអនុវត្តន៍សូចនាករតាមដានរួមគ្នា ។

សកម្មភាពនៃការបង្កើតសូចនាករតាមដានរួមគ្នាឆ្នាំ ២០១២ បង្ហាញយ៉ាងច្បាស់អំពីក្របខ័ណ្ឌផ្អែកលើលទ្ធផលមួយដែលប្រកបដោយគុណភាព ជាទិសដៅសំរាប់សកម្មភាពនានារបស់ក្រុមការងារចំរុះរាជរដ្ឋាភិបាល និងដៃគូ នៅក្នុងរយៈពេល២ឆ្នាំខាងមុខទៀត សំដៅសំរេចអោយបាននូវគោលបំណងចម្បងក្នុងការលើកកំពស់ការធ្វើផែនការផ្អែកលើលទ្ធផល និងរំលេចអោយកាន់តែច្បាស់អំពីបណ្តុំគោលការណ៍ដែលមាននៅក្នុងប្រសិទ្ធភាពជំនួយ ជាពិសេសសេចក្តីប្រកាសនៅទីក្រុងប៊ូសាន។

ដំណើរការនៃសូចនាករតាមដានរួមគ្នាថ្មីនេះ មានលក្ខណៈសំខាន់គួរឱ្យកត់សំគាល់មួយចំនួនដូចខាងក្រោម :

- លើកកំពស់ដំណើរការពិគ្រោះយោបល់ដែលកំពុងមាន រវាង និងក្នុងចំណោម ក្រុមការងារចម្រុះ ។
- ប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនូវសេវាគាំទ្របច្ចេកទេស និងសកម្មភាពសំរបសំរួលទាំងឡាយណាដែលផ្តល់ និងធ្វើដោយគណកម្មាធិការនិតិសម្បទានិងអភិវឌ្ឍន៍កម្ពុជារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើមុខសញ្ញាពង្រឹងសមត្ថភាពក្រុមការងារចម្រុះ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ក្នុងការបង្កើតនិងតាមដានសូចនាករតាមដានរួមគ្នា ។
- ពង្រឹងបន្ថែមនូវសង្គតិភាពរវាងក្របខ័ណ្ឌផ្សេងៗគ្នាដែលមានស្រាប់ទាក់ទងទៅនឹងលទ្ធផលនៃការអភិវឌ្ឍ ។
- បង្កើនការយល់ដឹងរបស់តួអង្គដែលធ្វើការពាក់ព័ន្ធនឹងក្របខ័ណ្ឌលទ្ធផល កម្មវិធី/ការគ្រប់គ្រងផ្អែកលើលទ្ធផល និងខ្សែសង្វាក់នៃលទ្ធផល ។
- ពង្រឹងការយល់ដឹងអំពីគោលការណ៍ SMART ដល់គ្រប់តួអង្គពាក់ព័ន្ធនៅក្នុងការកំណត់សូចនាករ ។

ដៃគូអភិវឌ្ឍន៍ សូមលើកឡើងនូវសំណើមួយចំនួនទៀតដើម្បីពង្រឹងដំណើរការសូចនាករតាមដានរួមគ្នា ។

- ខណៈដែលសូចនាករតាមដានរួមគ្នា ត្រូវបានបង្កើតឡើងតាមរយៈការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវក្របខ័ណ្ឌលទ្ធផលដែលមានស្រាប់ និងសូចនាកររបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏នៅមានចំនុចមួយចំនួនទៀតត្រូវការការសម្រឹតសម្រាំងបន្ថែមទៀត ជាពិសេសការធ្វើឱ្យសូចនាករតាមដានរួមគ្នាទាំងនេះ កាន់តែមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងទិសដៅគោលនយោបាយអភិវឌ្ឍន៍ និងសូចនាករ ដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា ។ ការយកចិត្តទុកអំពីទំនាក់ទំនងរវាងលទ្ធផល និងផលបន្តរបស់លទ្ធផលនេះ តម្រូវអោយមានការសម្របសម្រួលអន្តរស្ថាប័នប្រកបដោយប្រសិទ្ធភាពមួយ ជាពិសេសសំរាប់សូចនាករតាមដានរួមគ្នាណាដែល មានលក្ខណៈ "ឆ្លងវិស័យ" និងមានទំនាក់ទំនងទៅនឹងកំណែទម្រង់ទូលំទូលាយរបស់រដ្ឋ ។
- បន្ថែមលើការទទួលស្គាល់ថា សកម្មភាពបង្កើតសូចនាករតាមដានរួមគ្នាឆ្នាំ២០១២ជាសកម្មភាពប្រកបដោយការពិគ្រោះយោបល់ មានការចូលរួម និងមានភាពម៉ត់ចត់ នៅក្នុងដំណើរការបង្កើតសូចនាករតាមដានរួមគ្នា ការពង្រីកឱ្យមានការចូលរួមទូលំទូលាយជាងមុន ជាពិសេសឱ្យមានការចូលរួមរបស់សង្គមស៊ីវិល និងតួអង្គនៅថ្នាក់ក្រោមជាតិ